លេខ ៨ ចេញផ្សាយថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២២

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែមករា ឆ្នាំ២០២២

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## មាតិកា


- កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងវិសោធនកម្មប្រកាសស្តីពី "កម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច" ទំព័រ ១
- កិច្ចប្រជុំក្រុមការងារលើសេចក្តីព្រាងកម្រិតបច្ចេកទេសនៃចក្ខុវិស័យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្រិតថ្នាក់ដឹកនាំ ទំព័រ ២
- កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំឆ្នាំ ២០២១ ផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០២២ និងទិសដៅការងារប្រចាំឆ្នាំ២០២៣ ទំព័រ ២


## កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងវិសោធនកម្មប្រកាសស្តីពី "កម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច"

នៅព្រឹកថ្ងៃអង្គារ ៩កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ និយ័តករបរធនបាលកិច្ច (**ន.ប.ធ**) បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងវិសោធនកម្មប្រកាសស្តីពី "កម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ចនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

កិច្ចប្រជុំពិគ្រោះយោបល់នេះត្រូវបានរៀបចំឡើងក្នុងគោលបំណងទទួលបាននូវធាតុចូល និងមតិយោបល់បន្ថែមពីវិស័យឯកជន និងបុគ្គលពាក់ព័ន្ធនានា ដើម្បីឱ្យការរៀបចំប្រកាសនេះទទួលបាននូវភាពគ្រប់ជ្រុងជ្រោយ សំដៅដល់ការអនុវត្តប្រកបដោយសណ្តាប់ធ្នាប់ តម្លាភាព ប្រសិទ្ធភាព និងទំនុកចិត្តពីអ្នកចូលរួមនៅក្នុងវិស័យបរធនបាលកិច្ច និងឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃការអភិវឌ្ឍសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន។

កិច្ចប្រជុំពិគ្រោះយោបល់នេះមានអ្នកចូលរួមពីតំណាងបរធនបាលនៃបរធនបាលកិច្ចចុះបញ្ជី តំណាងក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស និងបុគ្គលពាក់ព័ន្ធផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច។



រូបភាពក្នុងកិច្ចប្រជុំពិគ្រោះយោបល់នៅសាលប្រជុំនៃអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ ដារ៉ា**។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំក្រុមការងារលើសេចក្ដីព្រាងកម្រិតបច្ចេកទេសនៃចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្រិតថ្នាក់ដឹកនាំ

នាព្រឹកថ្ងៃពុធ ១០កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អមដោយសហការី បានចូលរួមកិច្ចប្រជុំក្រុមការងារលើសេចក្ដីព្រាងកម្រិតបច្ចេកទេសនៃចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្រិតថ្នាក់ដឹកនាំតាមប្រព័ន្ធ Zoom ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងាររៀបចំចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្រិតថ្នាក់ដឹកនាំ។



រូបភាពក្នុងកិច្ចប្រជុំក្រុមការងារសេចក្ដីព្រាងកម្រិតបច្ចេកទេសនៃចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្រិតថ្នាក់ដឹកនាំតាមប្រព័ន្ធ Zoom ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប**។

## កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំឆ្នាំ២០២១ ផែនការសកម្មភាពការងារប្រចាំឆ្នាំ២០២២ និងទិសដៅការងារប្រចាំឆ្នាំ២០២៣

នៅថ្ងៃសុក្រ ១១ រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច បានដឹកនាំសហការីចូលរួមកិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំឆ្នាំ២០២១ ផែនការសកម្មភាពការងារប្រចាំឆ្នាំ២០២២ និងទិសដៅការងារប្រចាំឆ្នាំ២០២៣ របស់និយ័តករមូលបត្រកម្ពុជា នៅខេត្តព្រះសីហនុ ព្រមទាំងបានចូលរួមជាមតិយោបល់ទៅលើការរៀបចំ "ផែនការអភិវឌ្ឍន៍ស្ថាប័ននៃនិយ័តករមូលបត្រកម្ពុជាសម្រាប់រយៈពេល ៥ ឆ្នាំ (២០២២-២០២៦) ផងដែរ។




រូបភាពក្នុងកិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំឆ្នាំ២០២១ ផែនការសកម្មភាពការងារប្រចាំឆ្នាំ២០២២ និងទិសដៅការងារប្រចាំឆ្នាំ២០២៣ របស់និយ័តករមូលបត្រកម្ពុជា ក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា**។